ក

# មាតិកា

## I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២០.១០.២០១១ -ព្រះរាជក្រឹត្យ នស/រកត/១០១១/៩៣៥ ស្តីពី ការតែងតាំង អគ្គសវនករ ចំនួន ០១ រូប និង អគ្គសវនកររង ចំនួន ០២ រូប នៃអាជ្ញាធរសវនកម្មជាតិ ៧៩០៩

២០-១០-២០១១ -ព្រះរាជក្រឹត្យ នស/រកត/១០១១/៩៣៦ ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ចំនួន ០២ រូប ឱ្យបំពេញមុខងារជាអគ្គលេខាធិការរង នៃអាជ្ញាធរជាតិ ទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ៧៩១០


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


១៨-១០-២០១១ -អនុក្រឹត្យលេខ ២៣៣ អនក្រ.បក ស្តីពី ការបង្កើតវិទ្យាស្ថានជាតិសង្គមកិច្ច ៧៩១១

១៩-១០-២០១១ -អនុក្រឹត្យលេខ ១១២៣ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៧៩១៥

១៩-១០-២០១១ -អនុក្រឹត្យលេខ ១១២៤ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៧៩១៦

១៩-១០-២០១១ -អនុក្រឹត្យលេខ ១១២៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៧៩១៧

១៩-១០-២០១១ -អនុក្រឹត្យលេខ ១១២៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៧៩១៨

១៩-១០-២០១១ -អនុក្រឹត្យលេខ ១១២៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៧៩១៩

១៩-១០-២០១១ -អនុក្រឹត្យលេខ ១១២៨ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៧៩២០

១៩-១០-២០១១ -អនុក្រឹត្យលេខ ១១២៩ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៧៩២១


### ២-សេចក្តីសម្រេច


១៩.១០.២០១១ -សេចក្តីសម្រេចលេខ ៥៨ សសរ ស្តីពី ការបង្កើតគណៈកម្មាធិការបច្ចេកទេសចម្រុះ ទទួលបន្ទុកការកំណត់ព្រំដែន និង ការអភិវឌ្ឍរួមគ្នាលើធនធានប្រេងកាត នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នាកម្ពុជា-ថៃ ៧៩២៣


## III-ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល


២១-៩-២០១១ -ប្រកាសលេខ ៨៧១ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជី ស៊ីង ហ្គាមេន (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៧៩២៧

០៣.១០.២០១១ -ប្រកាសលេខ ៨៧៧ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ម៉ី រ៉េ អីភែរីល (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៧៩៣១

០៣.១០.២០១១ -ប្រកាសលេខ ៨៧៨ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្គាងស៊ីណាន់ហ្វៃវ៉ឺស មេថល គ្រុប (ខេមបូឌា) បង្កើតសហគ្រាសមន្ទីរពិសោធន៍ វិភាគរ៉ែ ៧៩៣៥

## ២_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៩-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៥៦២ ពណ.ចបព ស្តីពីការទទួលចុះបញ្ជីនូវការកែប្រែនិងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **អង្គរ ឡូតស ខាន់ទ្រី ក្លឹប** ៧៩៣៨

២៩-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៥៦៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប្រូខន ប៊ីលឌើរ** ៧៩៤០

២៩-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៥៦៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហាន ថុង អ៊ិនវេសមេន** ៧៩៤២

២៩-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៥៧៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់សាខាក្រុមហ៊ុន **ខាញ់ ខួយ៉េន ខនស្ត្រាក់សិន គ្រេឌីង ខមភេនី លីមីធីត** ៧៩៤៤

២៩-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៥៨៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់កុមហ៊ុន **គីម អិម ម៉ាយ អ៊ិនវេសមេន** ៧៩៤៥

# ព្រះរាជក្រឹត្យ

នស/រកត/១០១១/៩៣៥

## យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០៦/០២៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា១៨ នៃច្បាប់ស្ដីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៤ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១១ ស្ដីពីលទ្ធផលនៃការបោះឆ្នោតទុកចិត្តលើការតែងតាំងអគ្គសវនករ ចំនួន ០១ រូប និងអគ្គសវនកររង ចំនួន ០២ រូប នៃអាជ្ញាធរសវនកម្មជាតិ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានតែងតាំងអគ្គសវនករ ចំនួន ០១ រូប និងអគ្គសវនកររង ចំនួន ០២ រូប នៃអាជ្ញាធរសវនកម្មជាតិ ដែលមានសមាសភាព ដូចតទៅ :

១- លោកជំទាវ **សោម គឹមសួគ៌** ជាអគ្គសវនករ

២- ឯកឧត្ដម **ឆាយ គីម** ជាអគ្គសវនកររង

៣- ឯកឧត្ដម **សួន សិទ្ធី** ជាអគ្គសវនកររង ។

**មាត្រា២ :** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែ តុលា ឆ្នាំ ២០១១*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្ដីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

៣៦៤.១១១០.៩៥២

**សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

លេខ ៩១០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១

អគ្គលេខាធិការ [illegible] រាជរដ្ឋាភិបាល

[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១០១១/៩៣៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០០/១៩២ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ចំនួន ០២ រូប ឱ្យបំពេញមុខងារជាអគ្គលេខាធិការរង នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **ភួង សំណាង** មានឋានៈស្មើ **អគ្គនាយក**
២- ឯកឧត្តម **នាង ម៉ៅ** មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា២** : ត្រូវបានដំឡើងឋានៈជូនឯកឧត្តម **សួង ណាយ** អគ្គលេខាធិការរង នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា៣** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៥** : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២០ ខែ តុលា ឆ្នាំ ២០១១*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ពរស.១១១០.៩៤៣

លេខ: ៩៤៧ ច.ល
ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ ១០ ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល
សយ សុខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៣៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតវិទ្យាស្ថានជាតិសង្គមកិច្ច

## រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអប់រំ

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស

បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ

យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតវិទ្យាស្ថានជាតិសង្គមកិច្ច សរសេរកាត់ វ.ជ.ស ។ វ ជ ស មានទីតាំងស្ថិតនៅផ្លូវជួងងៀប ២ ភូមិដំណាក់ធំ ៣ សង្កាត់ ស្ទឹងមានជ័យ ខណ្ឌ មានជ័យ រាជធានីភ្នំពេញ។

## ជំពូកទី ២
## បេសកកម្ម និងរចនាសម្ព័ន្ធ

**មាត្រា ២.-**

**វ ជ ស** មានបេសកកម្មបណ្តុះបណ្តាល និងស្រាវជ្រាវលើផ្នែកសង្គមកិច្ច ដោយភ្ជាប់ទៅនឹងតម្រូវការរបស់ប្រទេសជាតិ និងសង្គម។

**មាត្រា ៣.-**

**វ ជ ស** មានឋានៈស្មើអគ្គនាយកដ្ឋាន និងស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា ៤.-**

**វ.ជ.ស.** ដឹកនាំដោយនាយកមួយរូប និងនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់។ ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ **វ.ជ.ស.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា ៥.-**

នាយក **វ.ជ.ស.** មានភារកិច្ចដូចខាងក្រោម៖

- បំពេញរាល់មុខងាររដ្ឋបាល និងគ្រប់គ្រងការងារទាំងឡាយ ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងបទបញ្ជាផ្ទៃក្នុងរបស់ **វ.ជ.ស.**
- អនុវត្តតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា និងគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ក្នុងក្របខណ្ឌធានាឱ្យមានគុណភាព និងប្រសិទ្ធភាពនៃការងារបណ្តុះបណ្តាល
- រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍ **វ.ជ.ស.**
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំសម្រាប់ **វ ជ.ស.** ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពិនិត្យ និងសម្រេច
- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់។

**មាត្រា ៦.-**

**ទ ជ ស** ធ្វើការបណ្តុះបណ្តាល កម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ លើមុខជំនាញសង្គមកិច្ច និងវិស្វកម្មឧបករណ៍សិប្បនិម្មិត និងរណប និងមានសាលាបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការគៀនឃ្លាំង និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការភ្នំពេញថ្មី សម្រាប់ធ្វើការបណ្តុះបណ្តាលក្រោមបរិញ្ញាបត្ររង។

**ទ ជ ស** អាចបើកមហាវិទ្យាល័យ សាលា មជ្ឈមណ្ឌល សាខា មុខជំនាញ កម្រិត ឬប្រភេទបណ្តុះបណ្តាលផ្សេងៗទៀត ទៅតាមលទ្ធភាព និងការចាំបាច់ ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី ៣
## កម្មវិធីសិក្សា លក្ខខណ្ឌជ្រើសរើស និងការផ្តល់សញ្ញាបត្រ

**មាត្រា ៧.-**

**ទ.ជ.ស** ត្រូវរៀបចំកម្មវិធីសិក្សាលម្អិតតាមថ្នាក់ និងមុខជំនាញ ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។ ការជ្រើសរើសសាស្ត្រាចារ្យមកបង្រៀនត្រូវអនុលោម តាមគោលការណ៍របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៨.-**

ការជ្រើសរើសនិស្សិតឱ្យចូលរៀននៅ **ទ.ជ.ស.** ត្រូវស្របតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៩.-**

និស្សិតដែលរៀនចប់តាមកម្មវិធីសិក្សា ក្រោមកម្រិតបរិញ្ញាបត្ររង និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សានៅ **ទ.ជ.ស.** ត្រូវទទួលវិញ្ញាបនបត្រ ឬសញ្ញាបត្រ តាមមុខជំនាញដែលបានសិក្សា។ វិញ្ញាបនបត្រ ឬ សញ្ញាបត្រនេះត្រូវផ្តល់ឱ្យដោយ **ទ.ជ.ស.** ហើយត្រូវទទួលស្គាល់ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

និស្សិតដែលរៀនចប់តាមកម្មវិធីសិក្សានៃកម្រិតបរិញ្ញាបត្ររង ឬបរិញ្ញាបត្រ និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សានៅ **ទ.ជ.ស** ត្រូវទទួលបានសញ្ញាបត្របរិញ្ញាបត្ររង ឬ បរិញ្ញាបត្រ តាមមុខជំនាញដែលបានសិក្សា។ សញ្ញាបត្របរិញ្ញាបត្ររង ឬ បរិញ្ញាបត្រ ត្រូវផ្តល់ឱ្យដោយ **ទ.ជ.ស.** ហើយត្រូវទទួលស្គាល់ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី ៤
## ប្រភពធនធាន

**មាត្រា ១០.-**

**ទ.ជ.ស** មានប្រភពធនធាន ដូចខាងក្រោម ៖

- ថវិកាជាតិដែលជាឧបសម្ព័ន្ធក្នុងកញ្ចប់ថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជ និងយុវនីតិសម្បទា

- ថវិកាដែលបានមកពីការបង់ថ្លៃសិក្សា
- ហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍនានា បរិច្ចាគរបស់សប្បុរសជន និងជំនួយឥតសំណង ឬកម្ចីដែលធ្វើឡើងតាមការយល់ព្រមពីរាជរដ្ឋាភិបាល។ **វ.ជ.ស.** មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិជំនួយផ្នែកបច្ចេកទេស និងសម្ភារៈផ្សេងៗទៀត ពីប្រភពក្នុង ឬក្រៅប្រទេស សម្រាប់បម្រើសេចក្តីត្រូវការក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***

*- ក្រសួងព្រះបរមរាជវាំង*
*- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*- អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*- អគ្គលេខាធិការរាជរដ្ឋាភិបាល*
*- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*- ដូចមាត្រា ១២*
*- រាជកិច្ច*
*- ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១២៣.អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសមាមេត្រី

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយសមាមេត្រី ថ្នាក់ សេនា** ចំនួន ០១ គ្រឿង ជូនអ្នកស្រី NINA SIEGERT មន្ត្រីជំនាញការបច្ចេកទេសផ្នែកធានារ៉ាប់រងសុខភាព និងរបបសន្តិសុខសង្គម នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាល្លឺម៉ង់(GIZ) ដែលមានស្នាដៃល្អ ក្នុងការធានារ៉ាប់រងសុខភាព និងរបបសន្តិសុខសង្គម ទទួលបានជោគជ័យគួរជាទីមោទនៈ នាពេលកន្លងមក។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១៧៨ . អនក្រ . បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយសហមេត្រី ថ្នាក់ សេនា ចំនួន ០១ គ្រឿង ជូនអ្នកស្រី MARYA DEWIN មន្ត្រីអង្គការយូនីសេហ្វ(UNICEF) ដែលមានស្នាដៃល្អ ក្នុងការសម្របសម្រួលនូវគោលនយោបាយអភិវឌ្ឍន៍ក្របខ័ណ្ឌការងារវិមជ្ឈការ និងវិសហមជ្ឈការ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទទួលបានជោគជ័យគួរជាទីមោទនៈ នាពេលកន្លងមក។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១១៧៥ . អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនក្រុមហ៊ុន FUJINO FOOD, Ltd ដែលបានផ្តល់ថវិកា ចំនួន ៥៦.៩០៥ ដុល្លារអាមេរិក តាមរយៈអង្គការ JHP ក្នុងការជួយកសាងអគារសិក្សា ០១ខ្នង មាន០៥បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់គ្រាន់ និងបង្គន់អនាម័យ ០១ខ្នង មាន០៤បន្ទប់ ជូនដល់សាលាបឋមសិក្សាទំនប់រលកថ្មី ស្ថិតនៅភូមិ៤ ឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ [illegible] ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១៧៦. អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនក្រុមហ៊ុន និងសប្បុរសជន ដែលបានផ្តល់ថវិកាជួយកសាងអគារសិក្សា នៅខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម ៖

១-ក្រុមហ៊ុន Amway Japan បានផ្តល់ថវិកាចំនួន ៤៩.៣៩៥ ដុល្លារអាមេរិក តាមរយៈអង្គការ JHP ជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៤បន្ទប់ បង្គន់អនាម័យ ០១ខ្នង មាន០៤បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារិមនិងជួយជីកស្រះទឹក ទំហំ១.៥០០ ម៉ែត្រគូប ជូនដល់សាលាបឋមសិក្សាជ្រៃរុន ស្ថិតនៅភូមិជ្រៃរុន ឃុំឫស្សីក្រាំង ស្រុកមោងឫស្សី ។

២-លោក គង់ សាខុន សប្បុរសជនខ្មែរ មកពីប្រទេសជប៉ុន បានផ្តល់ថវិកាចំនួន ៣៨.០០០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ០១ខ្នង មាន០៣បន្ទប់ ជូនដល់សាលាបឋមសិក្សាវត្តខ្សាច់វិជ្ជា ស្ថិតនៅភូមិមុខវត្ត ឃុំគាស់ក្រឡ ស្រុកគាស់ក្រឡ ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១៧៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក Kimura Shinya ដែលបានផ្តល់ថវិកា ចំនួន៥៦.១៩២ ដុល្លារ អាមេរិក តាមរយៈអង្គការ JHP ក្នុងការជួយកសាងអគារសិក្សា ០១ខ្នង មាន០៥បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់គ្រាន់ និងបង្គន់អនាម័យ ០១ខ្នង មាន០៤បន្ទប់ ជូនដល់សាលាបឋមសិក្សាជ្រៃបិទមាស ស្ថិតនៅភូមិជ្រៃ សង្កាត់វិហារលួង ក្រុងសួង ខេត្តកំពង់ចាម ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ១០ ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១២៨ .អនក្រ.បក

### អនុក្រឹត្យ
### ស្តីពីការផ្តល់មេដាយសុវត្ថារា

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ ជូនមន្ត្រីរាជការ ចំនួន ០៤រូប ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធាន ចូលរួមកសាង អភិវឌ្ឍន៍ សមិទ្ធផលនានា លើផ្នែកពុទ្ធចក្រ និងអាណាចក្រ នាពេលកន្លងមក ដូចមានរាយនាមខាងក្រោម៖

១-ឧត្តមសេនីយ៍ទោ គង់ តារាវណ្ណ អគ្គលេខ ០០១៣១៥ ទីប្រឹក្សាក្រសួងការពារជាតិ

២-លោក អៀវ ជី អនុប្រធាននាយកដ្ឋានក្រសួងព្រះបរមរាជវាំង

៣-លោក ជុំ សុផាណា មន្ត្រីគយ និងរដ្ឋាករ

៤-លោកស្រី មុត យ៉ង់សុនី អភិបាលរងខណ្ឌដូនពេញ

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១៧៩ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន ១៦រូប ដែលមានគុណបំណាច់ខ្ពស់ ដោយបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធាន ចូលរួមកសាង អភិវឌ្ឍន៍ សមិទ្ធផលនានា លើផ្នែកពុទ្ធចក្រ និងអាណាចក្រ នាពេលកន្លងមក ដូចមាននាយនាមខាងក្រោម៖

**ក-មេដាយ មុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

| | |
|---|---|
| ១-លោកស្រី **ឈឹម សុមុនី** | អនុប្រធាននាយកដ្ឋាននីតិវិធី នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា |
| ២-លោកវរសេនីយ៍ត្រី **សំ សុខត្ថានា** | អត្តលេខ១៩៩៨៣ កងរាជអាវុធហត្ថលើផ្ទៃប្រទេស |
| ៣-លោក **សុត ចាន់ឧណ្ណៈ** | អនុប្រធាននាយកដ្ឋានសង្គមកិច្ច |
| ៤-លោក **នួច សំអុល** | សប្បុរសជន |

**ខ-មេដាយ មុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

| | |
|---|---|
| -លោកស្រី **សំ មុណ្ណា** | អនុប្រធានការិយាល័យហិរញ្ញវត្ថុផ្នែកឧត្តមសិក្សា នៃនាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា |

**គ-មេដាយ មុនីសារាភ័ណ្ឌ ថ្នាក់អស្សឫទ្ធិ**

| | |
|---|---|
| ០១-វរសេនីយ៍ត្រី **មាស សុផា** | អត្តលេខ២០៥៩៦០ អធិការរងនគរបាលខណ្ឌឫស្សីកែវ |
| ០២-អនុសេនីយ៍ឯក **ខេខ ស្រេខ** | អត្តលេខ២០៨៨៩៤ អធិការនគរបាលស្រុកស្រីសន្ធរ |
| ០៣-អនុសេនីយ៍ទោ **ឃឹម សោវ៉ាឌណ្ណា** | អត្តលេខ១៧៥៩៣ ប្រធានប៉ុស្តិ៍ប្រាំងចំរេះ ១ |
| ០៤-លោក **ស៊ុន គីមលី** | ប្រធានក្រុមហ៊ុនជេ ស៊ី.បូអេគិ ថវិកា ៣០.២៥០ ដុល្លាអាមេរិក |
| ០៥-លោកស្រី **ជា គីម** | អនុប្រធានការិយាល័យហិរញ្ញវត្ថុផ្នែកឧត្តមសិក្សា នៃនាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា |
| ០៦-លោក **ខួន លក្ខណា** | អនុប្រធានការិយាល័យហិរញ្ញវត្ថុផ្នែកឧត្តមសិក្សា នៃនាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា |
| ០៧-លោក **ម៉ុក ស៊ីថា** | មន្ត្រីការិយាល័យហិរញ្ញវត្ថុផ្នែកឧត្តមសិក្សា នៃនាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា |
| ០៨-លោក **ទៅ ម៉េងអាន** | មន្ត្រីការិយាល័យហិរញ្ញវត្ថុផ្នែកឧត្តមសិក្សា នៃនាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា |

០៩-លោក **ម៉ុច ដារ៉ា** មន្ត្រីការិយាល័យហិរញ្ញវត្ថុផ្នែកឧត្តមសិក្សា នៃនាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា
១០-លោក **ជិន តារា** មន្ត្រីការិយាល័យហិរញ្ញវត្ថុផ្នែកឧត្តមសិក្សា នៃនាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា
១១-លោក **នុត ណៃរ៉ត** មន្ត្រីការិយាល័យហិរញ្ញវត្ថុផ្នែកឧត្តមសិក្សា នៃនាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ១០ ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៨.សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មាធិការបច្ចេកទេសចម្រុះទទួលបន្ទុកការកំណត់ព្រំដែន និងការអភិវឌ្ឍរួមគ្នាលើធនធានប្រេងកាតនៅក្នុងតំបន់ទាមទារ ដែនសមុទ្រត្រួតគ្នាកម្ពុជា-ថៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១០៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខជស/រកត/០១៩៨/០២០ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតអាជ្ញាធរប្រេងកាតជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២៩៨/៩០ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពគ្រប់គ្រងដឹកនាំនៃអាជ្ញាធរប្រេងកាតជាតិកម្ពុជា
- តាមសំណើរបស់ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីនិងជាប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា

## **សម្រេច**

**ប្រការ១** : បង្កើតគណៈកម្មាធិការបច្ចេកទេសចម្រុះទទួលបន្ទុកការកំណត់ព្រំដែន និងការអភិវឌ្ឍរួមគ្នាលើធនធានប្រេងកាតនៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នាកម្ពុជា-ថៃ ដែលមានសមាសភាពដូចតទៅ៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **សុខ អាន** | ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម | **ហេងខេង្យ ម៉ិនឆាត** | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ | ទីប្រឹក្សាជាន់ខ្ពស់ |
| ៣- ឯកឧត្តម | **វ៉ា គីមហុង** | ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការព្រំដែន | ទីប្រឹក្សាជាន់ខ្ពស់ |
| ៤- ឯកឧត្តម | **ច័ន្ទ សារី** | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | ទីប្រឹក្សាជាន់ខ្ពស់ |
| ៥- ឯកឧត្តម | **ឡុង វិសាលោ** | រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៦- ឯកឧត្តម | **ហូ វិចិត្រ** | អនុប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា | អនុប្រធាន |
| ៧- ឯកឧត្តម | **ឡាំ ជា** | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៨- ឯកឧត្តម | **វង្សី វិស្សុត** | អគ្គលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៩-ឯកឧត្តម | **ជា វ៉ាន់ដេត** | ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១០-ឯកឧត្តម | **សុខ ខាវ៉ាន់** | ទីប្រឹក្សាច្បាប់អាជ្ញាធរប្រេងកាតជាតិកម្ពុជា | សមាជិក |
| ១១-ឯកឧត្តម | **ស៊ឹម អៀង** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១២-ឯកឧត្តម | **ហួន សាវ៉ាង** | អនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន | សមាជិក |
| ១៣-ឧត្តមនាវីទោ | **គ្រួច គិមជុន** | នាយរងសេនាធិការកងទ័ពជើងទឹក | សមាជិក |
| ១៤-ឯកឧត្តម | **ម៉ម អំណាត់** | ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៥-លោក | **ម៉ែន ដែន** | អគ្គនាយករងអាជ្ញាធរប្រេងកាតជាតិកម្ពុជា | សមាជិក |
| ១៦-លោក | **ឡៀប សេរីវិសិទ្ធិ** | ជំនួយការផ្ទាល់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី | សមាជិក |
| ១៧-លោក | **កែរ វិសិដ្ឋ** | ប្រធាននាយកដ្ឋានច្បាប់-កុងស៊ុលនៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

| | | | |
|---|---|---|---|
| ១៨-លោក | **គង់ ច័ន្ទនាសនា** | ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិនៃទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៩-លោក | **ឃួន សុគន្ធា** | អនុប្រធានផ្នែកកិច្ចការច្បាប់និងចរចានៃអាជ្ញាធរប្រេងកាតជាតិកម្ពុជា | សមាជិក |
| ២០-លោក | **ញ៉ឹក សុមេធ** | អនុប្រធានផ្នែកកិច្ចការច្បាប់និងចរចានៃអាជ្ញាធរប្រេងកាតជាតិកម្ពុជា | លេខា |
| ២១-លោក | **អឿន សុខា** | មន្ត្រីអាជ្ញាធរប្រេងកាតជាតិកម្ពុជា | ជំនួយការលេខា |
| ២២-លោក | **អេន សុភាព** | មន្ត្រីអាជ្ញាធរប្រេងកាតជាតិកម្ពុជា | ជំនួយការលេខា |

**ប្រការ២** : គណៈកម្មាធិការបច្ចេកទេសចម្រុះទទួលបន្ទុកការកំណត់ព្រំដែន និងការអភិវឌ្ឍរួមគ្នាលើធនធានប្រេងកាតនៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នាកម្ពុជា-ថៃមានភារកិច្ច៖

(ក) ចរចារៀបចំសន្ធិសញ្ញា និងគ្រប់ប្រព័ន្ធច្បាប់គ្រប់គ្រងបទប្បញ្ញត្តិ គោលការណ៍ បទដ្ឋានទាំងអស់ដែលពាក់ព័ន្ធដល់ការអភិវឌ្ឍរួមគ្នានៃធនធានប្រេងកាតរាប់បញ្ចូលទាំងមូលដ្ឋានគ្រឹះដែលមានផលប្រយោជន៍ទៅវិញទៅមក និងអាចទទួលយកបានដោយភាគីទាំងពីរចំពោះការបែងចែកលើការចំណាយ និងផលចំណេញនៃការធ្វើអាជីវកម្មលើធនធានអ៊ីដ្រូកាបួរដែលស្ថិតនៅក្នុងតំបន់នៃការអភិវឌ្ឍរួមគ្នាដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

(ខ) ចរចារៀបចំសន្ធិសញ្ញាលើការបែងចែកព្រំដែនសមុទ្រដែនដីខ្ពង់រាបបាតសមុទ្រ និងតំបន់សេដ្ឋកិច្ចផ្ដាច់មុខ ដែលស្ថិតចន្លោះបន្ទាត់នៃការទាមទារដែនសមុទ្របច្ចុប្បន្នរៀងៗខ្លួនរបស់ប្រទេសទាំងពីរនៅក្នុងតំបន់ដែលត្រូវបែងចែកព្រំដែនអនុលោមទៅតាមបណ្ដាគោលការណ៍ទាំងឡាយដែលអាចអនុវត្តបាននៃច្បាប់អន្តរជាតិដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

(គ) ផ្អែកលើតម្រូវការចាំបាច់គណៈកម្មាធិការបច្ចេកទេសចម្រុះគ្នានេះ ត្រូវចុះអង្កេតផ្ទៀងផ្ទាត់រួមគ្នាលើនិយាមការ(កូអ័រដោណេ) នៃកោះ ថ្មប៉ប្រះទឹក ចំណុចនីមួយៗ និងអ្វីៗទាំងអស់ដែលមានលក្ខណៈពិសេស និងចរិតប្រវត្តិសាស្ត្រពាក់ព័ន្ធស្ថិតនៅក្នុងដែនដីគោក និងដែនសមុទ្រកម្ពុជា-ថៃ។

**ប្រការ៣** : គណៈកម្មាធិការបច្ចេកទេសចម្រុះគ្នានេះ ត្រូវជួបប្រជុំគ្នាឲ្យបានទៀងទាត់ក្នុងទស្សនៈសម្រេចឲ្យបាននូវការងាររបស់ខ្លួនទាក់ទងទៅនឹងបញ្ហាទាំងអស់នេះឲ្យបានឆាប់រួសរាន់។ គណៈកម្មាធិការបច្ចេកទេសចម្រុះគ្នានេះអាចបង្កើតឡើងនូវអនុគណៈកម្មាធិការឬក្រុមការងារដូចអ្វីដែលសមស្របទៅនឹងតម្រូវការចាំបាច់។

**ប្រការ៤** : គ្រប់សមាជិកនៃគណៈកម្មាធិការបច្ចេកទេសចម្រុះនេះ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន ឬ អនុប្រធានហើយគណៈកម្មាធិការនេះមានសិទ្ធិអញ្ជើញអ្នកបច្ចេកទេសចូលរួមតាមការចាំបាច់ និងត្រូវរាយការណ៍ជូនរាជរដ្ឋាភិបាលលើលទ្ធផលនៃការងាររបស់ខ្លួន។

**ប្រការ៥** : គណៈកម្មាធិការបច្ចេកទេសចម្រុះនេះមានទីស្នាក់ការរបស់ខ្លួននៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការ៦** : សេចក្តីសម្រេចលេខ៦២សសរ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៧** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ តុលា ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>ចម្លងជូន</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- ឯកសារ-កាលប្បវត្តិ

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ: ៥៧២ ឧ.រ.ថ.ភក ប្រក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
Nation Religion King

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១១

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ១៩០៧ /១១ គ.វ.ក ចុះថ្ងៃទី២៣.០៨.២០១១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ជី ស៊ីង ហ្គាមេន (ខេមបូឌា) ចុះថ្ងៃទី០៨.០៨.២០១១

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ជី ស៊ីង ហ្គាមេន (ខេមបូឌា) តំណាងដោយ លោក CHEN, CHAO-KUO សញ្ជាតិចិន(តៃវ៉ាន់) អាយុ៥១ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 210901900 ចុះថ្ងៃទី២២.០៤.២០០៨ មានអាសយដ្ឋានបច្ចុប្បន្ន៖ (350)15F, No.16, Lane 51, Min-Chuan St., Lin 12, Chu-Nan Li, Chu-Nan Town, Miaoli Country ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម ៖

| ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ ៨៥៥ ២៣-២១១១៤១ ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh. Phone: 855-23-211141, Fax: 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *" ជី ស៊ីង ហ្គាមេន (ខេមបូឌា)"*

*"(CHIH HSING GARMENT (CAMBODIA) CO., LTD.)"*

**ទីតាំងរោងចក្រ ៖** *" ផ្លូវជាតិលេខ៦A ភូមិខ្វរ សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

